ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៥ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារពិសេសតាមដានការអនុវត្ត គោលការណ៍របស់នាយករដ្ឋមន្ត្រីពាក់ព័ន្ធកិច្ចការងារសន្តិសុខសណ្តាប់ធ្នាប់សង្គម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការបង្កើតខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១ ..

ត្រូវបានបង្កើតក្រុមការងារពិសេសតាមដានការអនុវត្តគោលការណ៍របស់នាយករដ្ឋមន្ត្រីពាក់ព័ន្ធកិច្ចការងារសន្តិសុខសណ្តាប់ធ្នាប់សង្គម ចំណុះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម នាយឧត្តមសេនីយ៍	**ជួន សុវណ្ណ**	ប្រធាន
២. ឯកឧត្តម	**ហួត សុផល្លី**	អនុប្រធាន
៣. លោក	**ជាំង ឡូត**	សមាជិក
៤. លោក	**តាន់ ម៉េងស្រួយ**	សមាជិក
៥. លោក	**ម៉ែន ឌុច**	សមាជិក

https://www.moj.gov.kh/kh/law-regular

ការតែងតាំង និងការផ្លាស់ប្តូរសមាសភាពនៃក្រុមការងារពិសេស ត្រូវធ្វើឡើងតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមការស្នើរបស់ប្រធានក្រុមការងារពិសេស។

ក្រុមការងារពិសេស អាចបង្កើតក្រុមការងារចំណុះតាមការចាំបាច់ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមការស្នើរបស់ប្រធានក្រុមការងារពិសេស ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

ប្រការ២ ..

ក្រុមការងារពិសេសមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើជាសេនាធិការជូននាយករដ្ឋមន្ត្រីក្នុងការផ្តល់យោបល់ពាក់ព័ន្ធកិច្ចការងារសន្តិសុខសណ្តាប់ធ្នាប់សង្គម
- រាល់ការស្រាវជ្រាវ ប្រមូលព័ត៌មាន ចងក្រងទិន្នន័យ និងតាមដានពាក់ព័ន្ធកិច្ចការងារសន្តិសុខសណ្តាប់ធ្នាប់សង្គម ត្រូវស្នើសុំការសម្រេចជាមុនពីនាយករដ្ឋមន្ត្រី ឬតាមបទបញ្ជារបស់នាយករដ្ឋមន្ត្រី
- សិក្សា វាយតម្លៃ និងវិភាគជូននាយករដ្ឋមន្ត្រីពាក់ព័ន្ធកិច្ចការងារសន្តិសុខសណ្តាប់ធ្នាប់សង្គម
- សម្របសម្រួល ទំនាក់ទំនង និងសហការជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាននានាចំបាច់ ដើម្បីសម្រេចភារកិច្ចឲ្យមានប្រសិទ្ធភាពខ្ពស់
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

ប្រការ៣ ..

ក្រុមការងារពិសេស មានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិការបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

ប្រការ៤ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៥ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

https://www.moj.gov.kh/kh/law-regular